ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
**អគ្គនាយកដ្ឋានធនធានរ៉ែ**
លេខ..៣១៣.......អធរ.ជអ

**ដីកាអម**

**ផ្ញើជូន:** លោកនាយកអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
**យោង:** លិខិតលេខ ០២៨ DIP / NGOF/2012 ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១២

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | សៀវភៅបូកសរុបការងារធនធានរ៉ែឆ្នាំ២០១១ និងទិសដៅអនុវត្តការងារឆ្នាំ២០១២ | ០១ | |

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១២
**ហត្ថលេខាអ្នកទទួល**

ភ្នំពេញ, ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១២
**អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ**

ស្មុខ-ឡេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្តីពីសកម្មភាពអនុវត្តការងារឆ្នាំ ២០១១ និងទិសដៅការងារឆ្នាំ ២០១២ របស់អគ្គនាយកដ្ឋានធនធានរ៉ែ

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

អគ្គនាយកដ្ឋានធនធានរ៉ែ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២

# មាតិកា

**សេចក្តីផ្តើម**.....ទំព័រ ១

**I.លទ្ធផលការងារឆ្នាំ២០១១**.....ទំព័រ ១

**១-ការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ និងធនធានរ៉ែ**.....ទំព័រ១

ក-ការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ.....ទំព័រ១

ខ-ការងារសិក្សាស្រាវជ្រាវធនធានរ៉ែ.....ទំព័រ២

គ-ការងារអាជីវកម្មរ៉ែសំណង់.....ទំព័រ៤

**២-ការងារលិខិតបទដ្ឋាន និងចុះបញ្ជី**.....ទំព័រ៤

**៣-ការងារគ្រប់គ្រងទិន្នន័យ**.....ទំព័រ៤

**៤-ការងារសហប្រតិបត្តិការ និងបណ្តុះបណ្តាល**.....ទំព័រ៦

ក-ការងារសហប្រតិបត្តិការ.....ទំព័រ៦

ខ-ការងារបណ្តុះបណ្តាល.....ទំព័រ៧

**៥-ការងារចំណូលរដ្ឋ**.....ទំព័រ៩

**៦-ការងារយេនឌ័រ**.....ទំព័រ១២

**II.ទិសដៅការងារឆ្នាំ២០១២**.....ទំព័រ១៤

**សន្និដ្ឋាន**.....ទំព័រ១៥

**ឧបសម្ព័ន្ធ**.....ទំព័រ១៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**អគ្គនាយកដ្ឋានធនធានរ៉ែ**

# របាយការណ៍

# ស្តីពី

# សកម្មភាពអនុវត្តការងារ ឆ្នាំ២០១១

# និង ទិសដៅការងារឆ្នាំ២០១២ របស់អគ្គនាយកដ្ឋានធនធានរ៉ែ

## សេចក្តីផ្តើម

ដោយអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេច **អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ ឯកឧត្តមរដ្ឋមន្ត្រី **ស៊ុយ សែម** បាននឹងកំពុងជម្រុញវិស័យធនធានរ៉ែតាមរយៈការវិនិយោគឯកជនជាចម្បង ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ នៅក្នុងឆ្នាំ២០១១ អគ្គនាយកដ្ឋានធនធានរ៉ែ បានអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីជម្រុញការអភិវឌ្ឍន៍វិស័យធនធានរ៉ែឲ្យមានការរីកចំរើន ដោយពង្រឹងភាពជាដៃគូជាមួយវិនិយោគទុន ពង្រឹងការអនុវត្តច្បាប់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានពាក់ព័ន្ធនានាដើម្បីបង្កបរិយាកាសល្អសំរាប់ការវិនិយោគលើវិស័យធនធានរ៉ែ។

## I.លទ្ធផលការងារឆ្នាំ២០១១

### ១-ការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ និងធនធានរ៉ែ

#### ក-ការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ

- សរសេរអត្ថបទពន្យល់ជាភាសាខ្មែរស្តីពីភូគព្ភសាស្ត្រ និងធនធានរ៉ែ នៃខេត្តរតនគីរីបាន១០០%។
- ចុះសិក្សាផ្នែកភូគព្ភសាស្ត្ររ៉ែនៅលើទីវាលជាមួយអ្នកជំនាញការរបស់ JICA ប្រចាំការនៅអគ្គនាយកដ្ឋានធនធានរ៉ែនៅខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី រយៈពេល ០៥ថ្ងៃ។
- ចុះសិក្សាភូគព្ភសាស្ត្រ និងសម្រង់ទិន្នន័យរ៉ែត្បូងថ្មនៅតំបន់រៀងញ៉ង់ ស្រុកសៀមប៉ាង និងស្រុកសេសាន ខេត្តស្ទឹងត្រែងជាមួយក្រុមហ៊ុន Khun Sea Development Group Co,. Ltd.

- ចុះសម្រង់ទិន្នន័យភូគព្ភសាស្ត្រជម្រករ៉ែទង់ដែងនៅតាមតំបន់ត្រពាំងព្រីង និង តំបន់ក្រយ៉ា ស្រុកប្រាសាទបាល្ល័ង្គ ខេត្តកំពង់ធំ ជាមួយក្រុមហ៊ុន Wing Srun Co., Ltd។
- ចុះសម្រង់ទិន្នន័យភូគព្ភសាស្ត្រជាមួយក្រុមហ៊ុន VinaComin Group (មណ្ឌលគីរី), Angkor Metal Cooporation Co.,Ltd (បាត់ដំបង និងប៉ៃលិន)។
- ចុះសម្រង់ទិន្នន័យភូគព្ភសាស្ត្ររ៉ែត្បូងថ្ម នៅតំបន់ហាត់ប៉ក់ ស្រុកសេសាន ខេត្តស្ទឹងត្រែង ស្រុកវើនសៃ ខេត្តរតនៈគីរី របស់ក្រុមហ៊ុន Jin Gold Development Co., Ltd
- ចុះសម្រង់ទិន្នន័យរ៉ែលោហៈនៅតំបន់ភ្នំង៉ត និងតំបន់អូរប្លាយ ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី ជាមួយក្រុមហ៊ុន Gold Metals Group។
- ចុះសិក្សាភូគព្ភសាស្ត្រ និងសំរង់ទិន្នន័យភូគព្ភសាស្ត្រជាមួយក្រុមជំនាញរបស់ JOGMEC ក្នុងខេត្តតាកែវ និងខេត្តកំពត។
- ចុះសិក្សាភូគព្ភសាស្ត្រ និងសម្រង់ទិន្នន័យភូគព្ភសាស្ត្ររ៉ែលោហៈ និងរ៉ែត្បូងថ្មជាមួយក្រុមហ៊ុន Kep Power Supply Co., Ltd នៅតំបន់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
- ចូលរួមស្តាប់បទបង្ហាញរបស់ JOGMEC ស្តីពីលទ្ធផលនៃការចុះសិក្សាភូគព្ភសាស្ត្រនៅតំបន់ នៃខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់។
- ចុះសិក្សាភូគព្ភសាស្ត្រ និងសំរង់ទិន្នន័យរ៉ែលោហៈនៅតំបន់ភ្នំជី ស្រុកសណ្តាន់ ខេត្តកំពង់ធំ ជាមួយក្រុមហ៊ុន Alex Corporation.
- បានចុះអនុស្សរណៈស្តីពីការចុះស្រង់ទិន្នន័យភូគព្ភសាស្ត្ររ៉ែជាមួយក្រុមហ៊ុនបានចំនួន១៩។

## ខ-ការងារសិក្សាស្រាវជ្រាវធនធានរ៉ែ

ក្នុងឆ្នាំ២០១១ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានផ្តល់អាជ្ញាប័ណ្ណស្វែងរុករកជូនក្រុមហ៊ុនចំនួន២៤ ឲ្យធ្វើការសិក្សាស្រាវជ្រាវ និងវាយតម្លៃសក្តានុពលធនធានរ៉ែ មុននឹងឈានទៅចាប់ផ្តើមធ្វើអាជីវកម្ម ។ សកម្មភាពសិក្សាស្រាវជ្រាវស្វែងរុករករបស់ក្រុមហ៊ុនរ៉ែ ដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួងត្រូវបានសហការចូលរួមត្រួតពិនិត្យ និង ជំរុញការសិក្សាស្រាវជ្រាវដោយមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានធនធានរ៉ែ ។

សកម្មភាពសិក្សាស្រាវជ្រាវធនធានរ៉ែក្នុងឆ្នាំ២០១១ កន្លងមកនេះមានដូចតទៅ ៖

- បានចាត់មន្ត្រីសហការចុះសិក្សាស្រាវជ្រាវរ៉ែជាមួយក្រុមហ៊ុនៈ

  ១-ក្រុមហ៊ុនIndochine Resources Cambodia Limited កំពុងសិក្សាស្រាវជ្រាវរ៉ែមាសនៅខេត្តក្រចេះ និងខេត្តរតនគីរី Liberty Mining International Cambodia សិក្សាស្រាវជ្រាវរ៉ែមាសនៅខេត្តរតនៈគីរី និងក្រុមហ៊ុន Angkor Wat Cement Co., Ltd.។

២-ក្រុមហ៊ុន Sun Hill Minerals Co., Ltd សិក្សាស្រាវជ្រាវជម្រករ៉ែលោហៈនៅតំបន់អន្លង់ ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី និង ក្រុមហ៊ុន Angkor Wat Cement Co., Ltd។

៣-ក្រុមហ៊ុន Khmer Aggregates Company Limited ចុះសិក្សាស្រាវជ្រាវរ៉ែថ្មកំបោរនៅតំបន់ទូកមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត។

៤-ក្រុមហ៊ុនO D M J Coal Mine Co., Ltd និងក្រុមហ៊ុនHan Seng Coal Mine Co., Ltd ចុះសិក្សាស្រាវជ្រាវរ៉ែធ្យូងថ្មនៅតំបន់ក្រយ៉ា ត្រពាំងព្រីង និងសាគ្រាម ស្រុកសំបូរ ខេត្តកំពង់ធំ។

៥-ចាត់មន្ត្រីឲ្យចុះត្រួតពិនិត្យតាមដានក្រុមហ៊ុន JI ZHOU Co., Ltd នៅតំបន់ក្បាលតាតែ ភ្នំក្បាលប្រាំបី ស្រុកក្រចេះ និងស្រុកឆ្លូង ខេត្តក្រចេះ។

៦-ក្រុមហ៊ុន Allumina (Cambodia Ceitnam) Co., Ltd សិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែបុកស៊ីត នៅខេត្តមណ្ឌលគីរី។

- ចុះពិនិត្យសកម្មភាពការងារសិក្សាស្រាវជ្រាវរ៉ែលោហៈជាមួយក្រុមហ៊ុន United Khmer Group Co., Ltd នៅថ្មបាំង ស្រុកស្រែអំបិល ខេត្តកោះកុង។
- ចុះពិនិត្យ និងតាមដានសកម្មភាពការធ្វើអាជីវកម្មរ៉ែត្បូងថ្មរបស់ក្រុមហ៊ុន Ultra Marine Kiri (Cambodia) Co., Ltd. នៅតំបន់សែនថៅ ស្រុកសំឡូត ខេត្តបាត់ដំបង។
- សហការជាមួយអាជ្ញាធរមូលដ្ឋានបង្ក្រាបបានទាន់ពេលវេលា អំពីការធ្វើរ៉ែមាសបែបអនាធិបតេយ្យរបស់ប្រជាពលរដ្ឋ ស្ថិតនៅតំបន់ទីតាំងដីសម្បទានរបស់ក្រុមហ៊ុនPhu Yang (Cambodia) Co., Ltd នៅតំបន់ភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។
- រោងចក្រផលិតស៊ីម៉ង់ត៍ K-Cement កំពុងដំណើរការផលិតកម្ម។
- បូកសរុបរបាយការណ៍ស្តីពីលទ្ធផល នៃការអនុវត្តការងារសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែធ្យូងថ្ម និងធ្យូងភក់នៃក្រុមហ៊ុនវិនិយោគទុនផ្នែកធនធានរ៉ែធ្យូងថ្ម និងធ្យូភក់។
- បានធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវស្វែងរុករករ៉ែដែក នៅក្នុងដំណាក់កាលសិក្សាស្រាវជ្រាវទូទៅក្នុងឆ្នាំ ២០១០ និងផែនការសំរាប់សិក្សាស្រាវជ្រាវបន្តឆ្នាំ២០១១ នៅតំបន់អន្លង់ជ្រៃ និងអន្លង់ភេ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង របស់ក្រុមហ៊ុន The Steung Treng Mineral Joint Venture Company។
- ក្រុមហ៊ុន Southern Gold (Cambodia) Limited បានមកធ្វើបទបង្ហាញអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវកន្លងមក។
- បានចុះពិនិត្យវាយតំលៃទីតាំងស្នើសុំធ្វើអាជីវកម្មថ្មក្រានីតអាររបស់ក្រុមហ៊ុនZerlyCam Granite។
- ចូលរួមប្រជុំឆ្លង EIA របស់ក្រុមហ៊ុន Hoa Anh Rattanakiri និងUtramarinនៅក្រសួងបរិស្ថាន។
- ចូលរួមប្រជុំឆ្លង EIA របស់ក្រុមហ៊ុន Ultra marineKiri(Cambodia) Co., LTD ។
- ចូលរួមស្តាប់បទបង្ហាញរបស់ក្រុមហ៊ុន SINO SUN MINERAL RESOURCES Co.,Ltd ។
- បានចូលរួមស្តាប់បទបង្ហាញរបស់ក្រុមហ៊ុន K D Power Group Co.,Ltd ។

- បានចុះត្រួតពិនិត្យ និងតាមដានសកម្មភាពការងារអាជីវកម្មរ៉ែត្បូងថ្ម របស់ក្រុមហ៊ុន ULTRA MARIN KIRI (CAMBODIA) CO.,LTD នៅតំបន់សែនចៅ ស្រុកសំឡូត ខេត្តបាត់ដំបង ។

### គ- ការងារអាជីវកម្មរ៉ែសំណង់

នាយកដ្ឋានបានចេញអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មថ្មីចំនួន ៤៧ អាជ្ញាប័ណ្ណ និងការងារពន្យារបន្តអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម ចំនួន ១៤៧ អាជ្ញាប័ណ្ណ ព្រមទាំងបានបញ្ចប់កិច្ចព្រមព្រៀងថ្មសំភារៈសំណង់ចំនួន ៥០កិច្ចព្រមព្រៀង។ ទន្ទឹមនឹងនេះនាយកដ្ឋានកំពុងពិនិត្យ និងជូនដំណឹងទៅក្រុមហ៊ុនអាជីវករឲ្យដាក់ពាក្យសុំពន្យារបន្តអាជ្ញាបណ្ណ័តាមលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាប័ណ្ណ ។

ពាក់ព័ន្ធការត្រួតពិនិត្យ និងគ្រប់គ្រងលើសកម្មភាពអាជីវកម្មអនាធិបតេយ្យ នាយកដ្ឋានបានចុះអន្តរាគមន៍ និងបញ្ឈប់សកម្មភាពជីកកកាយដីស ដីក្រហម បូមខ្សាច់ អនាធិបតេយ្យ និងបានធ្វើការពិន័យតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ នៅតាមបណ្តាខេត្តមួយចំនួនដូចជាៈ ខេត្តកំពត ខេត្តព្រះសីហនុ និង ខេត្តពោធិ៍សាត់ជាដើម (ឧបសម្ព័ន្ធ) ។

## ២-ការងារលិខិតបទដ្ឋាន និងចុះបញ្ជី

- រៀបចំប្រកាសស្តីពីការកែសម្រួលប្រការ ២ នៃប្រកាសលេខ ៣៤០ ឧរថ.អធរ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការចុះបញ្ជី និងលក្ខខ័ណ្ឌនៃការផ្តល់ ការពន្យាបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ។
- បានចុះធ្វើបច្ចុប្បន្នភាពអាសយដ្ឋានក្រុមហ៊ុន ដែលបានចុះបញ្ជីធនធានរ៉ែរួចកន្លងមកបានចំនួន ៤៨ក្រុមហ៊ុន។
- បន្តរៀបចំកែសម្រួលប្រការកំណត់សួយសារធនធានរ៉ែ និងឈ្នួលដីប្រចាំឆ្នាំ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មធនធានរ៉ែបានចំនួន០៥ ក្រុមហ៊ុន។
- បានចេញអាជ្ញាប័ណ្ណសិក្សាស្រាវជ្រាវស្វែងរុករករ៉ែលោហៈចំនួន ២៤ អាជ្ញាប័ណ្ណក្រុមហ៊ុន
- បានចេញអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មចំនួន ៤៧ អាជ្ញាប័ណ្ណ។
- បានពន្យារបន្តអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម ចំនួន ១៤៧ អាជ្ញាប័ណ្ណ។
- បានពន្យារបន្តអាជ្ញាប័ណ្ណស្វែងរុករករ៉ែលោហៈចំនួន ២៩ អាជ្ញាប័ណ្ណ។
- បានចុះបញ្ជីធនធានរ៉ែចំនួន ២៨ ក្រុមហ៊ុន។
- បានបញ្ចប់កិច្ចព្រមព្រៀងថ្មសំភារៈសំណង់ចំនួន ៥០។
- បានបញ្ចប់កិច្ចព្រមព្រៀងសិក្សាស្រាវជ្រាវចំនួន១១។

## ៣-ការងារគ្រប់គ្រងទិន្នន័យ

- បាននឹងកំពុងរៀបចំចងក្រងមូលដ្ឋានទិន្នន័យរ៉ែត្បូងថ្ម តាមគំរោងសហប្រតិបត្តិការរវាងACE និង JCOAL ។
- បានបន្តបញ្ចូលតំបន់សម្បទានធនធានរ៉ែ តាមប្រព័ន្ធGIS និងDatabase ។
- បញ្ចូលទិន្នន័យអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម និងអាជ្ញាប័ណ្ណស្វែងរុករក ដើម្បីគ្រប់គ្រងសុពលភាព នៃអាជ្ញាប័ណ្ណតាមប្រព័ន្ធ Database។
- បានចងក្រងទិន្នន័យ នៃការធ្វើ អាជីវកម្មថ្មសំភារៈសំណង់ប្រចាំឆ្នាំ ២០១០ ។
- ពិនិត្យ និងតាមដានរបាយការណ៍ការងារប្រចាំត្រីមាសរបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត។
- ចេញលិខិតជូនដំណឹងបញ្ចប់កិច្ចព្រមព្រៀងសិក្សាស្រាវជ្រាវចំនួន ១២។

## ៤-ការងារសហប្រតិបត្តិការ និងបណ្តុះបណ្តាល

### ក- ការងារសហប្រតិបត្តិការ

- បានធ្វើកិច្ចសហប្រតិបត្តិការជាមួយ Kores ស្តីពីការសិក្សាAir Borne Survey នៅខេត្តស្ទឹងត្រែង រយៈពេល២សប្តាហ៍។
- បានចុះអនុស្សរណៈរវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង អង្គការ UNDP នៅថ្ងៃទី១៨ ខែមករា ដើម្បីធ្វើកិច្ចសហប្រតិបត្តិការលើកស្ទួយវិស័យធនធានរ៉ែ ឲ្យមានការអភិវឌ្ឍន៍ប្រកបដោយការទទួលខុសត្រូវ រួមមានការគាំទ្រដល់ការរៀបចំគោលនយោបាយរ៉ែជាតិ និងបទប្បញ្ញត្តិនានាដែលចាំបាច់ដើម្បីធានាឲ្យការគ្រប់គ្រងវិស័យរ៉ែនៅកម្ពុជាដំណើរការប្រកបដោយប្រសិទ្ធិភាព និងចិរភាព ។
- បង្កើតនូវផែនការអនុវត្តរយៈពេល០២ឆ្នាំ សម្រាប់ឆ្នាំ២០១១-២០១២ ក្នុងគោលបំណងជាសំខាន់នៃផែនការនេះ គឺជួយគាំទ្រដល់អគ្គនាយកដ្ឋានធនធានរ៉ែក្នុងការរៀបចំនូវគោលនយោបាយរ៉ែសម្រាប់កម្ពុជា ដោយផ្អែកទៅលើការអនុវត្តល្អៗរបស់ប្រទេសដែលមានឧស្សាកម្មរ៉ែជឿនលឿន និងគោលការណ៍នៃការធ្វើអាជីវកម្មរ៉ែប្រកបដោយការទទួលខុសត្រូវ ។
- ដើម្បីផ្តល់នូវទស្សនទានខ្លះៗក្នុងការរៀបចំគោលនយោបាយ UNDP ទីប្រឹក្សាផ្នែកឧស្សាហកម្មនិស្សារណកម្មរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិកម្ពុជាបានរៀបចំនូវសេរី នៃបទឧទ្ទេសនាមជាបន្តបន្ទាប់ក្នុងសិក្ខាសាលា ការសន្ទនាអំពីគោលនយោបាយចំនួន ៧លើក ដែលរួមមាន ៖
    1. គោលនយោបាយរ៉ែ - តួនាទីរបស់រដ្ឋ
    2. ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចរ៉ែ
    3. អាជីវកម្មរ៉ែប្រកបដោយការទទួលខុសត្រូវ

4. ពាណិជ្ជកម្ម និងថ្លៃរ៉ែ
5. អាជីវកម្មរ៉ែជាលក្ខណៈគ្រួសាររ៉ែ
6. បញ្ហាបរិស្ថានក្នុងអាជីវកម្មរ៉ែ
7. ប្រជាពលរដ្ឋសហគមន៍ សារៈសំខាន់ នៃអាជីវកម្មរ៉ែប្រកបដោយការទទួលខុសត្រូវ ទស្សនទាន និងគំនិតយោបល់ល្អៗដែលបានមកពីបទឧទ្ទេសនាម ឬ ការពិភាក្សាក្នុងសិក្ខាសាលា និងផ្តល់ជាប្រយោជន៍ដ៏សំខាន់ដល់ការរៀបចំតាក់តែងគោលនយោបាយរ៉ែជាតិសម្រប់កម្ពុជាដែលគ្រោងនឹងបញ្ចប់នាដំណាច់ឆ្នាំ២០១២ ខាងមុខនេះ ។

- ចូលរួមសិក្ខាសាលានៅ ITC ស្តីពីការផ្ទេរចំណេះដឹង និងលើកកំពស់យុវនិស្សិត វិស្វករជំនាន់ក្រោយនៃមហាវិទ្យាល័យធនធានរ៉ែ និងវិស្វកម្មភូគព្ភសាស្ត្រ។
- មន្ត្រីប្រាំ(០៥)រូប បានទៅចូលរួមសន្និសិទ្ធ និងតាំងពិពណ៌ស្តីពី(China-ASEAN Mining Cooperation Forum and Promotion Exhibition) នៅប្រទេសចិន ថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១១។
- មន្ត្រី ០១រូបចូលរួមប្រជុំថ្នាក់រដ្ឋមន្ត្រីថាមពលអាស៊ាននៅប្រទេសប្រ៊ុយណេ។
- ចូលរួមក្នុងសន្និសិទអន្តរជាតិ ស្តីពីការស្តារអណ្តូងរ៉ែជាមួយនឹងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព Mine Reclamation with Sustainable Development នៅប្រទេសកូរ៉េ។
- ចូលរួមស្តាប់បទបង្ហាញរបស់លោក Glenn Kendall មន្ត្រី UNDP ជូនដល់មន្ត្រីជំនាញរបស់ក្រសួងពាក់ព័ន្ធ ស្តីពីការរៀបចំសេចក្តីព្រាងគោលនយោបាយរ៉ែជាតិ។
- មន្ត្រី៣រូបចូលរួមប្រជុំថ្នាក់រដ្ឋមន្ត្រី AMMIN & ASOMM អាស៊ានប្រចាំឆ្នាំនៅទីក្រុងហាណូយ ប្រទេសវៀតណាម។

## ខ- ការងារបណ្តុះបណ្តាល

- បានសហការជាមួយ AOTS ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍រ៉ែសំរាប់កម្ពុជានៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ ថ្ងៃទី២២-២៦ ខែសីហា ឆ្នាំ២០១១ (រយៈពេល៥ថ្ងៃ)។
- ជំនាញការJICA រួមជាមួយមន្ត្រីអគ្គនាយកដ្ឋានបានធ្វើទស្សនកិច្ចសិក្សានៅខេត្តកំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគីរី និងខេត្តមណ្ឌលគីរី ពីថ្ងៃទី១៤-១៥ ខែមីនា ឆ្នាំ២០១១។
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់ឧស្សាហកម្មរ៉ែនៅកម្ពុជា (The Training Program On Human Resources Development On The Mining Industry For Cambodia) ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ នៅសណ្ឋាគារ Sunway ទីក្រុងភ្នំពេញ ដែលរៀបចំដោយ JICA។
- បានចូលរួមសិក្ខាសាលាស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ដោយចិរភាពនៅអគ្គនាយកដ្ឋានធនធានរ៉ែ និងអាជីវកម្មខ្នាតតូចជាលក្ខណៈសិប្បកម្មរៀបចំដោយ UNDP ចំនួន០២លើក។

- ចូលរួមសិក្សាវគ្គខ្លីស្តីពី " ក្របព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងនីតិវិធី នៃកសាងសំណុំរឿងរបស់នគរបាលយុត្តិធម៌ " នៅសកលវិទ្យាល័យបញ្ញាជាតិ។
- បានចូលរួមវគ្គបណ្តុះបណ្តាល GIS ,ការកំណាកំណើតសិលា និងវិធីសាស្រ្តស្វែងរុករករ៉ែនៅថ្ងៃទី ២៣-២៤ ខែវិច្ឆិកា ឆ្នាំ២០១១ ។
- បានជ្រើសរើសមន្ត្រីអគ្គនាយកដ្ឋានធនធានរ៉ែចំនួន(១២)រូប មន្ត្រីមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តចំនួន ០៥រូប និស្សិតវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា០១រូប និងបុគ្គលិកក្រុមហ៊ុនចំនួន ០៨រូប សំរាប់ទៅទទួលការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍រ៉ែសំរាប់កម្ពុជា ដែលរៀបចំដោយ AOTS នៅប្រទេសជប៉ុន ថ្ងៃទី២៦ ខែតុលា ដល់ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១។
- បញ្ជូនមន្ត្រី០១រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Ground Water Theory and Practice នៅប្រទេសកូរ៉េ។
- មន្ត្រី០១រូបបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Costal Geology and Costal Geohazards ថ្ងៃទី១៩-៣០ ខែកញ្ញា ឆ្នាំ២០១១ នៅប្រទេសកូរ៉េ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី GIS នៅសាធារណៈរដ្ឋកូរ៉េ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការធ្វើអាជីវកម្មរ៉ែប្រកបដោយប្រសិទ្ធភាព និងបរិស្ថានល្អ និងការប្រើប្រាស់ធនធានលោហៈឡើងវិញ (Efficient and Environment-Friendly Mining and Recycling for Metal Resources) នៅប្រទេសជប៉ុន។
- មន្ត្រីចំនួន ០៨រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់ឧស្សាហកម្មរ៉ែនៅកម្ពុជា (The Training Program On Human Resources Development On The Mining Industry For Cambodia) ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ នៅទីក្រុង Yokohama ប្រទេសជប៉ុន។
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងរ៉ែអាស៊ាន នៅប្រទេសជប៉ុន ចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១១។
- និស្សិត ០៩នាក់កំពុងសិក្សាថ្នាក់វិស្វករភូគព្ភសាស្រ្តនៅប្រទេសវៀតណាម។
- ទទួលនិស្សិតវិស្វករនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាចំនួន១៥នាក់ ឲ្យមកធ្វើកម្មសិក្សានៅតាមទីវាលនៃក្រុមហ៊ុនកំពុងសិក្សាស្រាវជ្រាវរ៉ែ។
- បញ្ជូនមន្ត្រី០១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី " National Economic Planning and Management " នៅមជ្ឈមណ្ឌលកម្ពុជា - សឹង្ហបុរី រាជធានីភ្នំពេញ។
- បញ្ជូនមន្ត្រី ០១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី " Intellectual Property Systems Management and Governance " នៅមជ្ឈមណ្ឌលកម្ពុជា - សឹង្ហបុរី រាជធានីភ្នំពេញ។

- មន្ត្រី ០២រូបចូលរួមសិក្សាវគ្គខ្លីស្តីពី " ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងនីតិវិធី នៃកសាងសំណុំរឿងរបស់នគរបាលយុត្តិធម៌ " នៅសកលវិទ្យាល័យបញ្ញាជាតិដែលប្រព្រឹត្តទៅនៅរៀងរាល់ថ្ងៃអាទិត្យ។
- ចូលរួមសិក្ខាសាលាស្តីពីការសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ សំរាប់ការអភិវឌ្ឍន៍សង្គមនៅប្រទេសចិន eological and Mineral Resources Management for Developing Countries in ChangChun City Jilin Procince, China.
- ចូលរួមវគ្គបណ្តុះបណ្តាលមុខជំនាញស្តីពី Geological Mapping Capacity Building for ASEAN Member Countries (Kunming, Yunnan Provine). នៅប្រទេសចិន។
- បានចូលរួមសិក្ខាសាលាស្តីពីគំរោងការ ការពារបរិស្ថាននៅតាមតំបន់ឆ្នេរ ដែលរៀបចំឡើងដោយក្រសួងបរិស្ថាននៅសណ្ឋាគារ Sun Way ក្រុងភ្នំពេញ។

## ៥-ការងារចំណូលរដ្ឋ

- តាមដាន និងជំរុញឲ្យក្រុមហ៊ុនសិក្សាស្រាវជ្រាវតម្កល់ប្រាក់ធានាការពូកិច្ចការងារនៅធនាគារជាតិនៃកម្ពុជាតាមសារាចរណែនាំលេខ ០៤ សហវ។
- ពិន័យចំពោះក្រុមហ៊ុន/អាជីវករដែលមិនព្រមបង់សួយសារ និងថ្លៃឈ្នួលដីសម្បទានតាមការកំណត់។
- ប្រមូលចំណូលពីថ្លៃចុះបញ្ជី ពាក្យសុំ (កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ និងថ្លៃឈ្នួលដីសិក្សាស្រាវជ្រាវ-អាជីវកម្ម។
- តាមដានចំណូលសួយសារថ្មសំភារៈសំណង់រាជធានី-ខេត្ត។
- ដឹកនាំគណកម្មការសួយសារថ្មសំភារៈសំណង់អន្តរក្រសួង ចុះកំណត់សួយសារប្រចាំឆមាសទី១ និងទី២ ឆ្នាំ២០១១ នៅទូទាំងប្រទេស។
- ចេញលិខិត និងធ្វើការតឹងទារថ្លៃឈ្នួលដីសម្បទានចំពោះក្រុមហ៊ុនដែលនៅយឺតយ៉ាវមិនទាន់បង់
- រៀបចំបញ្ជីតាមដានការប្រមូលចំណូលតាមរយៈបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ២០១១

### តារាងអនុវត្តការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យធនធានរ៉ែឆ្នាំ ២០១១

1 USD =4,000៛

| ល.រ | ប្រភពចំណូល | ផែនការចំណូល ២០១១ | ការអនុវត្តឆ្នាំ២០១១ | | ប្រៀបធៀបនិងផែនការចំណូល (%) |
|---|---|---|---|---|---|
| | | គិតជារៀល | គិតជារៀល | គិតជាដុល្លារ | |
| ១ | ថ្លៃចុះបញ្ជីធនធានរ៉ែ | 40,560,000.00 | 30,000,000.00 | 7,500.00 | 73.96% |

| | | | | | |
|---|---|---|---|---|---|
| ២ | ពាក្យសុំ (កម្រែអាជ្ញាប័ណ្ណ) ធនធានរ៉ែ | 134,400,000.00 | 264,800,000.00 | 66,200.00 | 197.02% |
| ៣ | ថ្លៃពន្យារបន្តអាជ្ញាប័ណ្ណធនធានរ៉ែ | 353,300,000.00 | 240,520,000.00 | 60,130.00 | 68.08% |
| ៤ | ថ្លៃផ្ទេរសិទ្ធិអាជ្ញាប័ណ្ណធនធានរ៉ែ | 111,500,000.00 | 88,000,000.00 | 22,000.00 | 78.92% |
| ៥ | ឈ្នួលដីអាជីវកម្មថ្មសំភារៈសំណង់ | 960,380,000.00 | 1,674,879,840.00 | 418,719.96 | 174.40% |
| ៦ | ឈ្នួលដីសម្បទានរ៉ែ | 2,971,360,000.00 | 2,608,569,840.00 | 652,142.46 | 87.79% |
| ៧ | ឈ្នួលដីអាជីវកម្មរ៉ែ និងថ្មកំបោរ | 270,000,000.00 | 427,974,000.00 | 106,993.50 | 158.51% |
| ៨ | សួយសារថ្មកំបោរ ថ្មអារ ថ្មកែវ | 452,000,000.00 | 769,269,960.00 | 192,317.49 | 170.19% |
| ៩ | ពិន័យ ២% ពីការយឺតយាវក្នុងការបង់ថ្លៃ ឈ្នួលដី និងសួយសារ | 20,500,000.00 | 322,235,040.00 | 80,558.76 | 1571.88% |
| | **សរុប** | **5,314,000,000.00** | **6,426,248,680.00** | **1,606,562.17** | |

## សួយសារថ្មសំភារៈសំណង់រាជធានី-ខេត្ត

| ល.រ | ប្រភពចំណូល | ផែនការចំណូល ២០១១ | | ការអនុវត្តឆ្នាំ២០១១ | | ប្រៀបធៀបនិងផែនការចំណូល(%) |
|---|---|---|---|---|---|---|
| | | គិតជារៀល | គិតជាដុល្លារ | គិតជារៀល | គិតជាដុល្លារ | |
| ១ | រាជធានីភ្នំពេញ | 384,356,800 | 96,089.20 | 326,918,600 | 81,729.65 | 85% |
| ២ | ខេត្តកណ្តាល | 1,308,880,000 | 327,220.00 | 616,943,400 | 154,235.85 | 47% |
| ៣ | ខេត្តសៀមរាប | 152,600,000 | 38,150.00 | 155,400,000 | 38,850.00 | 102% |
| ៤ | ខេត្តកំពង់ស្ពឺ | 1,347,380,000 | 336,845.00 | 1,258,511,200 | 314,627.80 | 93% |
| ៥ | ខេត្តកំពង់ចាម | 307,880,000 | 76,970.00 | 323,400,000 | 80,850.00 | 105% |
| ៦ | ខេត្តកំពត | 567,000,000 | 141,750.00 | 398,200,000 | 99,550.00 | 70% |
| ៧ | ខេត្តកែប | 9,200,000 | 2,300.00 | 9,200,000 | 2,300.00 | 100% |
| ៨ | ខេត្តតាកែវ | 157,200,000 | 39,300.00 | 156,400,000 | 39,100.00 | 99% |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | ខេត្តព្រៃវែង | 44,000,000 | 11,000.00 | 58,800,000 | 14,700.00 | 134% |
| ១០ | ខេត្តកំពង់ឆ្នាំង | 24,800,000 | 6,200.00 | 13,600,000 | 3,400.00 | 55% |
| ១១ | ខេត្តពោធិ៍សាត់ | 32,200,000 | 8,050.00 | 32,200,000 | 8,050.00 | 100% |
| ១២ | ខេត្តបាត់ដំបង | 105,400,000 | 26,350.00 | 105,400,000 | 26,350.00 | 100% |
| ១៣ | ខេត្តបន្ទាយមានជ័យ | 222,760,000 | 55,690.00 | 212,888,000 | 53,222.00 | 96% |
| ១៤ | ខេត្តឧត្តរមានជ័យ | 82,000,000 | 20,500.00 | 28,000,000 | 7,000.00 | 34% |
| ១៥ | ខេត្តព្រះសីហនុ | 8,294,400 | 2,073.60 | 8,294,400 | 2,073.60 | 100% |
| ១៦ | ខេត្តរតនគិរី | 24,000,000 | 6,000.00 | 24,000,000 | 6,000.00 | 100% |
| ១៧ | ខេត្តកំពង់ធំ | 40,400,000 | 10,100.00 | 26,000,000 | 6,500.00 | 64% |
| ១៨ | ខេត្តព្រះវិហារ | 66,705,480 | 16,676.37 | 42,705,480 | 10,676.37 | 64% |
| ១៩ | ខេត្តក្រចេះ | 340,046,400 | 85,011.60 | 352,446,400 | 88,111.60 | 104% |
| ២០ | ខេត្តមណ្ឌលគិរី | 6,000,000 | 1,500.00 | 6,000,000 | 1,500.00 | 100% |
| ២១ | ខេត្តកោះកុង | - | - | - | - | - |
| ២២ | ខេត្តប៉ៃលិន | - | - | - | - | - |
| ២៣ | ខេត្តស្ទឹងត្រែង | - | - | - | - | - |
| ២៤ | ខេត្តស្វាយរៀង | - | - | - | - | - |
| | **សរុប** | **5,231,103,080** | **1,307,775.77** | **4,155,307,480** | **1,038,826.87** | 79% |

## ស្ទួយសារខ្សាច់សមុទ្រនាំចេញ

| ល.រ | ប្រភពចំណូល | ផែនការចំណូល ២០១១ | | ការអនុវត្តឆ្នាំ២០១១ | | ប្រៀបធៀប ធៀប និងផែនការ ចំណូល(%) |
|---|---|---|---|---|---|---|
| | | គិតជារៀល | គិតជាដុល្លារ | គិតជារៀល | គិតជាដុល្លារ | |

| | | | | | | |
|---|---|---|---|---|---|---|
| 1 | ខេត្តព្រះសីហនុ | 0.00 | 0.00 | 69,600,000 | 17,400.00 | |
| 2 | ខេត្តកោះកុង | 0.00 | 0.00 | 14,400,000 | 3,600.00 | |
| 3 | ខេត្តកំពត | 0.00 | 0.00 | 84,800,000 | 21,200.00 | |
| | **សរុប** | **0.00** | **0.00** | **168,800,000** | **42,200.00** | |

## ៦-ការងារយេនឌ័រ

អគ្គនាយកដ្ឋានធនធានរ៉ែមានមន្ត្រីចំនួន ៩៨នាក់ ក្នុងនោះស្ត្រីមានចំនួន ១០នាក់ ។

អនុវត្តតាមអនុសាសន៍**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** អគ្គនាយកដ្ឋានធនធានរ៉ែបានទទួលមន្ត្រីជាស្ត្រីដែលក្រសួងបានជ្រើសរើសឲ្យចូលបំរើការងារជាបន្តបន្ទាប់ដែលពីមុនយើងមានស្ត្រីតែម្នាក់ប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្ននេះមានចំនួនរហូតដល់ ១០នាក់ដែលក្នុងនោះស្ត្រីមានតួនាទីជាអនុប្រធាននាយកដ្ឋាន ០១នាក់ និងជាអនុប្រធានការិយាល័យ ០១នាក់ ។

- ឆ្នាំ២០១១កន្លងទៅនេះមន្ត្រីជានារីចំនួន ០៥នាក់ បានទៅចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន ស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់ឧស្សាហកម្មរ៉ែ នៅកម្ពុជា ។
- បានចូលរួមទិវានារីអន្តរជាតិគំរប់ខួបលើកទី១០០ នៅមជ្ឈមណ្ឌលកោះពេជ្រ។
- បានចូលរួមការផ្សព្វផ្សាយសៀវភៅផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាន ឆ្នាំ ២០១១-២០១៥។
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយអនុសញ្ញា ស៊ី-ដ បន្តពិធីសារតាមជម្រើស និងត្រួតពិនិត្យអនុវត្តផែនការយុត្តិសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នាថ្ងៃទី ១៣-១៤ ខែមិថុនា ឆ្នាំ២០១១ នៅសណ្ឋាគារសាន់វ៉េ។
- ប្រជុំពិភាក្សាអំពីដំណើរការសកម្មភាព របស់សមាគមនារី និងផ្សព្វផ្សាយលក្ខន្តិកៈថ្មី។
- បានចូលរួមកិច្ចប្រជុំលើកទី៤របស់គណកម្មាធិការសម្របសម្រួលរួមនៅក្រសួងកិច្ចការនារី។
- បានចូលរួមសិក្ខាសាលាលើកទី៤របស់គម្រោងបញ្ជ្រាបយេនឌ័រដំណាក់កាលទី២(PGM2) នៅក្រសួងកិច្ចការនារី។
- បានទទួលចុះបញ្ជីធនធានរ៉ែជូនដល់ក្រុមហ៊ុនដែលនាយកជាស្ត្រីចំនួន ១០ក្រុមហ៊ុន។

## ៧-បញ្ហាផ្សេងៗ

- បានចូលរួមពិធីប្រកាសផ្ទេរភារៈកិច្ច និងតែងតាំងប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តព្រះវិហារ កែប ក្រចេះ ស្ទឹងត្រែង និងកំពង់ស្ពឺ។
- ចូលរួមចំតាំងពិព័រណ៍ក្នុងព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល និងខួបលើកទី២០នៃការនិវត្ត របស់ព្រះមហាវរៈក្សត្រ។
- ចូលរួមស្តាប់បទបង្ហាញរបស់ក្រុមហ៊ុន Cambodia Certification & Inspection Private Co., Ltdស្តីពីសំណើសុំអាជ្ញាប័ណ្ណធ្វើជាស្ថាប័នកោសលវិច័យឯកភាគីទី៣ នៅព្រះរាជាណាចក្រកម្ពុជា។
- ចូលរួមប្រជុំពិភាក្សាពីគោលនយោបាយដីធ្លីនៅក្រសួងដែនដី នគររូបនីយកម្ម និងសំណង់។
- ចូលរួមប្រជុំពិភាក្សាលើសេចក្តីព្រាងសេវាសាធារណៈ នៅក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល។
- ចូលរួមក្នុងពិធីធ្វើប្រតិភូកម្មការងារអនុវត្តន៍ការគ្រប់គ្រងសារធាតុគីមី និងការចុះបញ្ជីផលិតផលក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានចូលរួមប្រជុំផ្តល់យោបល់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងខួងរកប្រេង ប្លុក F ដែលមានទីតាំងនៅខេត្តព្រះសីហនុរបស់ក្រុមហ៊ុន CNOOC International Limited ។
- បានចូលរួមស្តាប់បទបង្ហាញស្តីពីបច្ចេកវិជ្ជាទំនើបអំពីការសិក្សាស្រាវជ្រាវរ៉ែរបស់ក្រុមហ៊ុនមកពីប្រទេសរុស្ស៊ី។
- ចេញលិខិតជូនដំណឹងបញ្ចប់កិច្ចព្រមព្រៀងដល់ក្រុមហ៊ុនសិក្សាស្រាវស្រាវរ៉ែ ចំនួន១២ ។
- ចូលរួមប្រជុំក្រុមការងារទារបំណុលអន្តរក្រសួងចំនួន២លើក នៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។
- ចូលរួមស្តាប់ធម្មសាការ ក្នុងកម្មវិធីនាទី " ព្រះពុទ្ធសាសនា ផ្សារភ្ជាប់នឹងសង្គម " នៅទីស្តីការក្រសួងធម្មការ និងសាសនា ។
- ការរៀបចំដំឡើងថ្នាក់ និងកម្រិតប្រាក់បំណាច់មុខងារប្រចាំឆ្នាំ ២០១២ ជូនមន្ត្រីរាជការ។
- ស្នើសុំគ្រឿងឥស្សរិយយសឆ្នាំ២០១១ជូនមន្ត្រីរាជការដែលមានស្នាដៃល្អ។
- ស្រង់ស្ថិតិកម្រិតវប្បធម៌ទូទៅ និងកម្រិតបច្ចេកទេសជំនាញរបស់មន្ត្រីរាជការប្រចាំឆ្នាំ ២០១២។
- ជួយសំរួលបែបបទឲ្យក្រុមហ៊ុន ODMJ Coal Mine Co., Ltd សុំនាំចេញដី និងថ្មគំរូរ៉ែ (Sample) ចំនួន០៦ គីឡូក្រាម យកទៅធ្វើការពិសោធន៍ និងវិភាគនៅប្រទេសថៃ, ចំនួន១៣.៦០ គីឡូក្រាម របស់ក្រុមហ៊ុន Wing Srun Co., Ltd, ចំនួន១៥.៥០ គីឡូក្រាម របស់ក្រុមហ៊ុន Han Seng Coal Co., Ltd និងចំនួន១.៧៣ គីឡូក្រាម របស់ក្រុមហ៊ុន Indochine Resources Co., Ltd និងក្រុមហ៊ុន Indochine Resources (Cambodia) Limited សុំនាំចេញដី និងថ្មគំរូរ៉ែ (Sample) ចំនួន៦៣ គីឡូក្រាម យកទៅធ្វើការពិសោធន៍ និងវិភាគនៅប្រទេសឡាវ ( តាមច្រកទ្វារអន្តរជាតិដុំក្រឡ ).
- រៀបចំសុំនាំចេញថ្មគំរូរ៉ែ (Sample) ចំនួន៤២គីឡូក្រាម យកទៅមន្ទីរពិសោធន៍នៅប្រទេសថៃ ( តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ) របស់ក្រុមហ៊ុន Khmer Aggregates Company Limited ។

- សុំនាំចេញដី និងថ្មគំរូរ៉ែ (Sample) ចំនួន ២,០០០(ពីរពាន់) គីឡូក្រាមយកទៅធ្វើការពិសោធន៍ និងវិភាគ នៅប្រទេសឡាវ ( តាមច្រកទ្វារអន្តរជាតិដុំក្រឡ ) របស់ក្រុមហ៊ុន OZ Mineral (Cambodia) Limited និងក្រុមហ៊ុន Liberty Mining International Pty.Ltd.
- សុំនាំគំរូរ៉ែ (Sample) ដើម្បីយកទៅធ្វើការពិសោធន៍ និងវិភាគនៅប្រទេសឡាវ (តាមច្រកទ្វារព្រលានយន្តហោះអន្តរជាតិភ្នំពេញ) របស់ក្រុមហ៊ុន Nam Hai Mineral Joint Stock Company.
- សុំនាំគំរូរ៉ែ (Sample) ដើម្បីយកទៅធ្វើការពិសោធន៍ និងវិភាគនៅប្រទេសកាណាដា (តាមច្រកទ្វារព្រលានយន្តហោះអន្តរជាតិភ្នំពេញ) របស់ក្រុមហ៊ុន Z.TAKRY MINING JOINTSTOCK LTD.
- សុំនាំគំរូរ៉ែ (Sample) ដើម្បីយកទៅធ្វើការពិសោធន៍ និងវិភាគនៅប្រទេចិន (តាមច្រកទ្វារ ព្រលានយន្តហោះអន្តរជាតិភ្នំពេញ) របស់ក្រុមហ៊ុន Cambodia WS Mining Holding Limited.
- សុំនាំគំរូរ៉ែ (Sample) ដើម្បីយកទៅធ្វើការពិសោធន៍ និងវិភាគនៅប្រទេសហ្វីលីពីន (តាមច្រកទ្វារព្រលានយន្តហោះអន្តរជាតិភ្នំពេញ) របស់ក្រុមហ៊ុន Southern Gold (Cambodia) Ltd.
- សុំនាំគំរូរ៉ែ (Sample) ដើម្បីយកទៅធ្វើការពិសោធន៍ និងវិភាគនៅប្រទេសអូស្ត្រាលី (តាមច្រកទ្វារព្រលានយន្តហោះអន្តរជាតិភ្នំពេញ) របស់ក្រុមហ៊ុន Mining Hong Xin Co., Ltd.

## II.ទិសដៅការងារឆ្នាំ ២០១២

ដោយផ្អែកលើលទ្ធផលការងារអនុវត្តឆ្នាំ ២០១១ អគ្គនាយកដ្ឋានបានរៀបចំទិសដៅការងារសម្រាប់ឆ្នាំ ២០១២ មានដូចខាងក្រោម ៖

- រៀបចំកសាងគោលនយោបាយរ៉ែជាតិក្រោមការជួយគាំទ្រ និងសហការជាមួយ UNDP ។
- កសាងច្បាប់ស្តីពីសុវត្ថិភាពអណ្តូងរ៉ែ និងសុខភាព ក្រោមការជួយគាំទ្រ និងសហការជាមួយ JICA។
- បន្តចងក្រងអត្ថបទពន្យល់អំពីភូគព្ភសាស្ត្រ និងធនធានរ៉ែគ្រប់ខេត្ត-ក្រុង និងសិក្សាតំបន់នានាអំពីភូគព្ភសាស្ត្រសំរាប់ធ្វើការអភិរក្ស។
- ចាត់វិធានការបង្ក្រាប និងលុបបំបាត់ការធ្វើអាជីវកម្មរ៉ែសំណង់អនាធិបតេយ្យនៅទូទាំងប្រទេស ។
- បង្កើតក្រុមអធិការកិច្ចរបស់អគ្គនាយកដ្ឋានធនធានរ៉ែដើម្បីចុះតាមបណ្តាខេត្ត - រាជធានី
- ដកហូតអាជ្ញាប័ណ្ណចំពោះក្រុមហ៊ុន/អាជីវកម្ម ដែលមិនបានចាប់ផ្តើមប្រតិបត្តិការក្នុងដំណាក់ការពន្យារបន្តលើកទី២ ។
- កសាងទីតាំងជម្រករ៉ែ និងសន្និស្សរ៉ែទូទាំងប្រទេស
- រៀបចំគេហទំព័ររបស់អគ្គនាយកដ្ឋានធនធានរ៉ែឲ្យកាន់តែទំនើប និងងាយស្រួលដល់អ្នកវិនិយោគ
- រៀបចំប្លង់មេរបស់ការដ្ឋានអណ្តូងរ៉ែបើកឲ្យសមស្របតាមលក្ខណៈបច្ចេកទេសទំនើបមិនប៉ះពាល់បរិស្ថាន-សង្គម ។

- រៀបចំ និងកែលម្អបទដ្ឋានបច្ចេកទេសសម្រាប់ការដ្ឋានអណ្តូងរ៉ែបើក
- បន្តចុះបោះបង្គោលកំណត់ទីតាំងសម្បទានរបស់ក្រុមហ៊ុន/អាជីវករដែលធ្វើអាជីវកម្មរ៉ែសំណង់។
- ត្រួតពិនិត្យ និងកំណត់បរិមាណផលិតផលរ៉ែដែលក្រុមហ៊ុន/អាជីវកររ៉ែផលិតបាន ដើម្បីកំណត់ការបង់សួយសារជូនរដ្ឋ ។
- រៀបចំលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ដើម្បីគ្រប់គ្រងវិស័យធនធានរ៉ែឲ្យមានប្រសិទ្ធភាព ។
- រៀបចំយន្តការថ្មីដើម្បីកំណត់ទំតាំងរ៉ែសំណង់ឲ្យមានលក្ខណៈសមស្រប និងមិនប៉ះពាល់ដល់បរិស្ថាន ។
- ចាត់វិធានការតឹងទារបំណុលដែលក្រុមហ៊ុនជំពាក់រដ្ឋលើថ្លៃឈ្នួលផ្ទៃក្រឡា និងសួយសារ។ បន្តបណ្តុះបណ្តាលមន្ត្រីការិយាល័យធនធានរ៉ែ នៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្តឲ្យយល់ដឹងបន្ថែមលើការអនុវត្តន៍ច្បាប់ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងរ៉ែ ព្រមទាំងមុខជំនាញភូគព្ភសាស្ត្ររ៉ែដែលចាំបាច់មួយចំនួនថែមទៀតដើម្បីពង្រឹងការគ្រប់គ្រង និងការធ្វើអាជីវកម្មរ៉ែឲ្យមានប្រសិទ្ធិភាព ។
- ណែនាំក្រុមហ៊ុន/អាជីវកររ៉ែសំណង់ ដែលដឹកជញ្ជូនរ៉ែចេញពីការដ្ឋានលើផ្លូវសាធារណៈឲ្យចេះការពារផលប៉ះពាល់ផ្សេងៗ ។
- សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការចុះកំណត់សួយសារដែលបានធ្វើអាជីវកម្មក្រោមរូបភាពគ្មានអាជ្ញាប័ណ្ណដែលមានត្រឹមលិខិតអនុញ្ញាតពីមន្ទីរ ឬ អាជ្ញាធរស្រុក ខេត្ត - ក្រុងរាជធានី ដើម្បីប្រមូលចំណូលចូលរដ្ឋ និងមានវិធានការលុបបំបាត់ភាពអសកម្មទាំងនេះ ។
- បន្តអនុវត្តការងារតាមផែនការមេរបស់អគ្គនាយកដ្ឋានដែល JICA បានជួយរៀបចំ។
- បន្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និង អន្តរជាតិ។
- ពិនិត្យ និងវាយតម្លៃរបាយការណ៍បច្ចេកទេសនៃការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មធនធានរ៉ែដែលក្រុមហ៊ុននីមួយៗដាក់ជូនក្រសួងពិនិត្យ និងសំរេច។

## <u>សេចក្តីសន្និដ្ឋាន</u>

សម្រាប់ឆ្នាំ២០១១នេះក៏ដូចជាឆ្នាំកន្លងមក ដោយមានការដឹកនាំចង្អុលបង្ហាញ និងគាំទ្រឥតសំចៃពីសំណាក់ថ្នាក់ដឹកនាំក្រសួង ជាពិសេសឯកឧត្តមរដ្ឋមន្ត្រី អគ្គនាយកដ្ឋានធនធានរ៉ែរួមជាមួយ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត ដែលជាសេនាធិការ បានខិតខំពុះពារជំនះនូវរាល់ការលំបាក ដើម្បីសំរេចឲ្យបាននូវទិសដៅរបស់ខ្លួនក្នុងការគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែប្រកបដោយ ប្រសិទ្ធភាព តម្លាភាព និងធានាបាននូវការការពារបរិស្ថានប្រកបដោយនិរន្តរភាពសំដៅចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ ។

ជាយោគជ័យរបស់វិស័យនេះពីមួយថ្ងៃទៅមួយថ្ងៃកាន់តែត្រូវបានពង្រឹង និងពង្រីកឲ្យកាន់តែមានការរីកចំរើន ដោយមានក្រុមហ៊ុនមកចូលបណ្តាក់ទុនវិនិយោគកាន់តែកើនឡើង ហើយជាលទ្ធផលចំណូលរដ្ឋ

ពីវិស័យនេះក៏មានការកើនឡើងគួរឲ្យសំគាល់ ។ អគ្គនាយកដ្ឋានធនធានរ៉ែប្តេជ្ញាបន្តអនុវត្តភារកិច្ចរបស់ខ្លួនស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយបន្តប្រមូល រៀបចំចងក្រងទិន្នន័យផែនទី សក្តានុពលរ៉ែ ច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ និងកែលម្អការគ្រប់គ្រងស្របតាមផែនការមេរបស់អង្គការ JICA ដើម្បីឆ្លើយតបចំពោះសន្ទុះកំណើននៃការចូលមកបណ្តាក់ទុនវិនិយោគឯកជនក្នុងវិស័យធនធានរ៉ែទាំងក្នុង និងក្រៅប្រទេស ។ ពិសេសជាងនេះទៀតចំពោះកង្វះខាតធនធានមនុស្សស្ថិតក្រោមការខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានទាក់ទាញភាគីជប៉ុនឲ្យជួយជម្រុញការបើកមហាវិទ្យាល័យទេពកោសល្យធនធានរ៉ែ និងភូគព្ភសាស្ត្រឡើងវិញជាលទ្ធផលភាគីជប៉ុនបានជួយឲ្យមហាវិទ្យាល័យនេះបានដំណើរការចាប់ពីឆ្នាំសិក្សា២០១១-២០១២ នេះតទៅដូចការរំពឹងទុក។

ការសង្ឃឹម និងរំពឹងទុកអ្វីជាក្តីកង្វល់ត្រូវបានកាត់បន្ថយជាបណ្តើរៗ ភាពប្រឈមពីធនធានមនុស្សជាពិសេសលទ្ធផលនៃការសិក្សាស្រាវជ្រាវស្វែងរុករកបានបង្ហាញឲ្យឃើញថាសក្តានុពលរ៉ែមួយចំនួនដូចជា ៖ រ៉ែមាស ទង់ដែង ដែក និងធ្យូងថ្មនឹងត្រូវបានគេចាប់ផ្តើមធ្វើអាជីវកម្មរ៉ែលើកដំបូងទៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ដែលនឹងក្លាយជាសមិទ្ធផលថ្មីដែលសំរេចបានក្នុងវិស័យធនធានរ៉ែ ។

# របាយការណ៍អាជីវកម្មសំរាប់ឆ្នាំ២០១១

| ប្រចាំខែ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ការ.ថ្ម សំណង់ | ពន្យារបន្ត | 4 | 0 | 8 | 7 | 1 | 10 | 7 | 8 | 0 | 3 | 5 | 4 | 57 |
| | ចេញអាជ្ញាបណ្ណ | 4 | 0 | 0 | 0 | 2 | 1 | 3 | 0 | 0 | 1 | 1 | 3 | 15 |
| | បញ្ចប់អាជ្ញាបណ្ណ | 0 | 2 | 2 | 3 | 1 | 3 | 1 | 0 | 3 | 0 | 0 | 1 | 16 |
| ការ.ខ្សាច់ សំណង់ | ពន្យារបន្ត | 2 | 1 | 4 | 1 | 1 | 9 | 4 | 7 | 0 | 16 | 20 | 0 | 65 |
| | ចេញអាជ្ញាបណ្ណ | 2 | 1 | 4 | 0 | 4 | 1 | 0 | 2 | 0 | 2 | 0 | 6 | 22 |
| | បញ្ចប់អាជ្ញាបណ្ណ | 0 | 0 | 0 | 0 | 0 | 12 | 6 | 0 | 2 | 2 | 0 | 2 | 24 |
| ការ.ថ្មអារ-ថ្មចម្លាក់-និងដីឥដ្ឋសំណង់ | ពន្យារបន្ត | 2 | 0 | 1 | 0 | 0 | 1 | 0 | 4 | 0 | 5 | 3 | 3 | 19 |
| | ចេញអាជ្ញាបណ្ណ | 3 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 2 | 7 |
| | បញ្ចប់អាជ្ញាបណ្ណ | 1 | 0 | 1 | 0 | 0 | 9 | 0 | 0 | 0 | 0 | 0 | 1 | 12 |
| | សរុប | 18 | 4 | 20 | 11 | 9 | 48 | 21 | 21 | 5 | 29 | 29 | 22 | |
| សរុបអាជ្ញាបណ្ណ | | 185 | | | | | | | | | | | | |